ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១២ លេខ ២១ សប្តាហ៍ទី ៣ ថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០១២

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាវជាមុន)

មាតិកា

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសំរេច សារាចរ ប្រកាស

p

ក

មាតិកា

I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៨-០២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/១៦៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ២២ រូប ១៩៧៣

០៦-៣-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៣១២/១៨៦ ស្តីពី ការដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការ ចំនួន ០៤ រូប ពីវរមន្ត្រី ទៅឧត្តមមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួងស្ថាប័ន ១៩៧៤

០៦-៣-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៣១២/១៨៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ ទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល មន្ត្រីនគរបាលជាតិ និង សប្បុរសជន ចំនួន ៦៩ រូប ១៩៧៦

០៦-៣-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៣១២/១៩០ ស្តីពី ការតែងតាំង ឯកឧត្តម ប្រាក់ ចំរើន ជា ឧកញ៉ា ១៩៧៨

០៩-៣-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៣១២/១៩១ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម សូ ស៊ីនឹម មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយទទួលមរណភាព ១៩៧៩

០៩-៣-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៣១២/១៩២ ស្តីពី ការកែសម្រួលឋានន្តរស័ក្តិ លោកជំទាវ ចាន់ សំដារិទ្ធ ពីអនុមន្ត្រីថ្នាក់លេខ ១១ ទៅឧត្តមមន្ត្រីថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាករណីពិសេស នៅក្រសួងព្រះបរមរាជវាំង ១៩៨០

០៩-៣-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៣១២/១៩៣ ស្តីពី ការដាក់មន្ត្រីរាជការ ០៣ រូប ឱ្យចូលនិវត្តន៍ ក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងព្រះបរមរាជវាំង ដោយរក្សាមុខដំណែងជាអ្នកនយោបាយ ១៩៨១

០៩-៣-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៣១២/១៩៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំនៃក្រសួងពាណិជ្ជកម្ម ចំនួន ១៦ រូប ១៩៨២

០៩-៣-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៣១២/១៩៥ ស្តីពី ការប្តូរ និង តម្លើងប្រភេទក្របខ័ណ្ឌលោកស្រី ចំនួន ០២ រូប ជាករណីពិសេស នៅក្រសួងសាធារណការ និង ដឹកជញ្ជូន ១៩៨៣

II. រាជរដ្ឋាភិបាល

អនុក្រឹត្យ

១៣-៣-២០១២-អនុក្រឹត្យលេខ ៣៩ អនក្រ.បក ស្ដីពី ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ១៩៨៤
១៣-៣-២០១២-អនុក្រឹត្យលេខ ៤០ អនក្រ.បក ស្ដីពី ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ១៩៨៦
១៣-៣-២០១២-អនុក្រឹត្យលេខ ៤១ អនក្រ.បក ស្ដីពី ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ១៩៨៨
១៦-៣-២០១២ -អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្ដីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៣២១ ហិកតា ក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង ស្ថិតនៅក្នុងភូមិសាស្ត្រ ខេត្តកោះកុង ១៩៩០
១៦-៣-២០១២ -អនុក្រឹត្យលេខ ៤៣ អនក្រ.បក ស្ដីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៨.៥៦៨ ហិកតា ក្នុងតំបន់ឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ " គីរីរម្យ " ស្ថិតនៅក្នុងភូមិសាស្ត្រ ខេត្តកំពង់ស្ពឺ និង ខេត្តព្រះសីហនុ ១៩៩២
០៩-៣-២០១២ -អនុក្រឹត្យលេខ ២៧៣ អនក្រ.តត ស្ដីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ១៩៩៤
១៣-៣-២០១២-អនុក្រឹត្យលេខ ២៨៣ អនក្រ.តត ស្ដីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ១៩៩៦
១៣-៣-២០១២-អនុក្រឹត្យលេខ ២៨៤ អនក្រ.តត ស្ដីពី ការតែងតាំង ប្រគល់ភារកិច្ច និង ផ្ទេរភារកិច្ច ជូនមន្ត្រីរាជការ ១៩៩៧
១៣-៣-២០១២-អនុក្រឹត្យលេខ ២៨៥ អនក្រ.តត ស្ដីពី ការតែងតាំង ផ្លាស់ប្ដូរមុខងារ នាយទាហាន ១៩៩៩
១៤-៣-២០១២ -អនុក្រឹត្យលេខ ២៨៦ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ២០០១
១៤-៣-២០១២ -អនុក្រឹត្យលេខ ២៨៧ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ២០៥៩
១៤-៣-២០១២ -អនុក្រឹត្យលេខ ២៨៨ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ២០៦០
១៤-៣-២០១២ -អនុក្រឹត្យលេខ ២៨៩ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ២០៦១
១៤-៣-២០១២ -អនុក្រឹត្យលេខ ២៩០ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ២០៦៣
-អនុក្រឹត្យលេខ ២៩១,២៩២,២៩៣ អនក្រ.តត មិនទាន់បានទទួល
១៤-៣-២០១២ -អនុក្រឹត្យលេខ ២៩៤ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ២០៦៤

III. ការិយាល័យបណ្ដាក្រសួង

១. ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២៣-០២-២០១២-ប្រកាសលេខ ១៧៦ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ប៊ី & អិនហ្វាមេន (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ២០៦៥

២៣-០២-២០១២-ប្រកាសលេខ ១៧៧ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អាន់ស៊ីង (ខេមបូ) ហ្គាមេន ហ្វាក់តូរី លីមីធីត បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ២០៦៩
២៣-០២-២០១២-ប្រកាសលេខ ១៧៨ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្គោល ផ្លាវអឺរ នីតធីង បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ (ចាក់) ២០៧៣
២៣-០២-២០១២-ប្រកាសលេខ ១៧៩ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ភេសជ្ជៈកម្ពុជា បង្កើតរោងចក្រ ផលិតភេសជ្ជៈ ២០៧៧

២-លិខិតរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៣-០១-២០១១-លិខិតបញ្ជាក់លេខ ០១៤៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វ្រីគ័រ-ស៊ីវ អ៊ិនវេសមេន អិលធីឌី** ២០៨១
១៣-០១-២០១១-លិខិតបញ្ជាក់លេខ ០១៤៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ចាយថ៍ ហ្គោល អ៊ិមផត អិចផត** ២០៨៣
១៣-០១-២០១១-លិខិតបញ្ជាក់លេខ ០១៥១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អូស៊ិន ថេគណូឡូជី** ២០៨៥
១៣-០១-២០១១-លិខិតបញ្ជាក់លេខ ០១៥២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វីតុន គ្រុប (ខេមបូឌា)** ២០៨៧
១៣-០១-២០១១-លិខិតបញ្ជាក់លេខ ០១៥៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជីន ហាយ ឈាន់ អ៊ិនធើណេសិនណាល អេក្សប្លរិងលង់ ឌីវេឡុបមេន** ២០៨៩
១៣-០១-២០១១-លិខិតបញ្ជាក់លេខ ០១៥៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីឌីស លីវើរ ត្រាវែល & ធួរ** ២០៩១

p

ព្រះរាជក្រឹត្យ

នស/រកត/០២១២/១៦៧

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ២២ រូប បានបំពេញការងារសំខាន់ៗ និងមានស្នាដៃក្នុងការចូលរួមកសាង
និងអភិវឌ្ឍន៍ប្រទេសជាតិ

នូវ

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ឯកឧត្តម ឃឹម ស៊ុនសូដា ២- ឯកឧត្តម កោ វីរុ
៣- ឧកញ៉ា លឹម ហ៊ួរនីត្ត ៤- លោក សួន សាវេត
៥- លោកស្រី គីម សេដ្ឋានី ៦- លោក ជួន ណារិន

ខ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

- លោក នុត ពុធដារ៉ា

គ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

១- លោក ជឿង ស៊ុន ២- លោក ពុធ ទ្រី
៣- លោក ពៅ សុត្រ ៤- លោកស្រី ស៊ុំ ចិន្ដា

ឃ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

១- ឯកឧត្តម ឃុន វ៉ាង ២- លោក ប៊ុត ប៊ុនធឿន
៣- លោក លី គីមហ៊ាង ៤- លោក អ៊ុក វីរ៉ា
៥- លោក លឹម ហ៊ួរនីរ៉ា

ង- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

- លោកជំទាវ ឈុន ស៊ីណោ

ច- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** :

១- ឯកឧត្តម ស៊ិន ហ៊ួរ ២- ឯកឧត្តម ហុង ឆាយ
៣- លោក ខៀវ វ៉ាន់ស៊ី ៤- លោក អ៊ុន តាំ
៥- លោក វ៉ាន់ សារឿយ

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ២០១២
លេខ ... ច.ល
...រាជរដ្ឋាភិបាល
ស៊ុយ សុខា

៣៣៣.១២០២.១៣៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១២

p

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/១៩៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១.. ត្រូវបានដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការចំនួន ០៤ រូប ពីវរមន្ត្រី ទៅឧត្តមមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួង ស្ថាប័ន ដូចមានរាយនាមខាងក្រោម៖

ក្រសួងព័ត៌មាន				
ល.រ	នាម និង គោត្តនាម	ភេទ	ឋានន្តរស័ក្តិ និងថ្នាក់ចាស់	ឋានន្តរស័ក្តិ និងថ្នាក់ស្នើសុំ
[illegible]	[illegible] ម៉ារ៉ាទី	ប	ពីវរមន្ត្រី ថ្នាក់លេខ ៦	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦

ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ				
ល.រ	នាម និង គោត្តនាម	ភេទ	ឋានន្តរស័ក្តិ និងថ្នាក់ចាស់	ថ្នាក់ស្នើសុំ
១	**សាត សមុទ្រ**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤
២	**ឡេង សែ**	ប	ពីវរមន្ត្រី ថ្នាក់លេខ ៥	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥

មាត្រា២.. បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣.. សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៤.. ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៦៤.១២០៣.១៩១

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១២

លេខៈ ១៥៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១២

[illegible]ទី១នៃរាជរដ្ឋាភិបាល

[illegible]យ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/១៧៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល មន្ត្រីនគរបាលជាតិ និងសប្បុរសជន ចំនួន ៦៥រូប
ដែលមានស្នាដៃល្អ និងគុណបំណាច់ជាច្រើន ក្នុងការចូលរួមកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ

នូវ

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ឯកឧត្តម **បែនសុន សម័យ** ២- ឯកឧត្តមបណ្ឌិត **ថេង ច័ន្ទសង្វារ**
៣- ឧត្តមសេនីយ៍ទោ **រស់ សារ៉ាន់** ៤- ឧត្តមសេនីយ៍ត្រី **សួន រី**

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

១- ឯកឧត្តម **ឡាច ទូច** ២- វរសេនីយ៍ឯក **ឆាង សារិ**
៣- វរសេនីយ៍ឯក **អ៊ុំ ណារី** ៤- វរសេនីយ៍ទោ **ឃឹម សំអូន**
៥- វរសេនីយ៍ទោ **អ៊ុក ស៊ីថា** ៦- វរសេនីយ៍ទោ **ម៉ៅ ចន្ទ័តារ៉ា**
៧- វរសេនីយ៍ទោ **អេង វុត្ថា** ៨- វរសេនីយ៍ទោ **ព្រំ ស៊ីថា**
៩- វរសេនីយ៍ទោ **កែវ សំណាង** ១០- វរសេនីយ៍ទោ **ឡុង រ៉េន**
១១- វរសេនីយ៍ត្រី **កង ហួន** ១២- វរសេនីយ៍ត្រី **នាក់ ណារ៉ូ**

គ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

១- វរសេនីយ៍ឯក **ប៊ុន ចាន់ធី** ២- វរសេនីយ៍ទោ **ហៃម សេត**
៣- វរសេនីយ៍ទោ **ឈា ប្រាំង** ៤- វរសេនីយ៍ទោ **អ៊ុត សុភាព**
៥- វរសេនីយ៍ទោ **មិត្ស ពុទ្ធារិន** ៦- វរសេនីយ៍ទោ **ហង្ស សុផាត**
៧- វរសេនីយ៍ត្រី **សុខ សា** ៨- វរសេនីយ៍ត្រី **ប៊ុង ផាន់ណារ៉ា**
៩- អនុសេនីយ៍ឯក **សែម កែវភក្តី** ១០- អនុសេនីយ៍ឯក **ជាម សុខ**
១១- អនុសេនីយ៍ឯក **ព្រំ សារ៉ាន់** ១២- លោក **ចៅ ប៊ុនធី**

p

ឃ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

១- អនុសេនីយ៍ឯក	**ហ៊ុន**	**វាសនា**	២- អនុសេនីយ៍ឯក	**គាប**	**ជៀក**
៣- អនុសេនីយ៍ទោ	**ស៊ុង**	**យ៉ាវ**	៤- អនុសេនីយ៍ទោ	**យូ**	**ធីតា**
៥- អនុសេនីយ៍ទោ	**សាន**	**សាំង**	៦- អនុសេនីយ៍ទោ	**ម៉ី**	**សារិន**
៧- អនុសេនីយ៍ទោ	**នាក់**	**សុខ**	៨- អនុសេនីយ៍ទោ	**ប៊ុក**	**សោភ័ណ្ឌ**
៩- អនុសេនីយ៍ទោ	**ហ៊ុន**	**ហ៊ន**	១០- អនុសេនីយ៍ទោ	**សំ**	**ហេម**
១១- អនុសេនីយ៍ទោ	**មាស**	**ប៊ុណ្ណា**	១២- អនុសេនីយ៍ទោ	**អ៊ុម**	**ផាត**
១៣- អនុសេនីយ៍ត្រី	**សាត**	**ញ៉ូ**	១៤- អនុសេនីយ៍ត្រី	**ទុំ**	**ចិន្តា**
១៥- អនុសេនីយ៍ត្រី	**ពាន**	**សុខុម**	១៦- ព្រិន្ទបាលឯក	**សែម**	**លីនី**
១៧- លោក	**ទៀង**	**ដារិទ្ធ**	១៨- លោក	**ផា**	**ផល្លី**
១៩- លោក	**នូ**	**ភិរម្យ**			

ង- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សប្ញទ្ធិ** :

១- អនុសេនីយ៍ទោ	**និត**	**ដារ៉េត**	២- អនុសេនីយ៍ទោ	**ជួប**	**គឹង**
៣- អនុសេនីយ៍ទោ	**អ៊ុំ**	**វុទ្ធា**	៤- អនុសេនីយ៍ទោ	**សោម**	**ផល្លី**
៥- អនុសេនីយ៍ទោ	**ម៉ាង**	**ប្រកប**	៦- អនុសេនីយ៍ទោ	**សាន**	**សុខុម**
៧- អនុសេនីយ៍ត្រី	**លឹម**	**ម៉េងហ៊**	៨- អនុសេនីយ៍ត្រី	**ពៅ**	**វិទ្ធី**
៩- អនុសេនីយ៍ត្រី	**ស្រី**	**សុខា**	១០- អនុសេនីយ៍ត្រី	**ម៉ន**	**សុខា**
១១- អនុសេនីយ៍ត្រី	**នី**	**ស៊ីន**	១២- អនុសេនីយ៍ត្រី	**ហង្ស**	**សុផល**
១៣- អនុសេនីយ៍ត្រី	**ហ៊ែល**	**ធឿន**	១៤- អនុសេនីយ៍ត្រី	**ឃី**	**ចាន់ធី**
១៥- អនុសេនីយ៍ត្រី	**ស្រី**	**ណារត្ន័**	១៦- អនុសេនីយ៍ត្រី	**ពិន**	**ឃុន**
១៧- ព្រិន្ទបាលឯក	**មិន**	**សឿន**	១៨- ព្រិន្ទបាលឯក	**សូ**	**ម៉ន**
១៩- ព្រិន្ទបាលឯក	**គីម**	**អាន**	២០- ព្រិន្ទបាលឯក	**ផន**	**បៀន**
២១- ព្រិន្ទបាលឯក	**សៅ**	**សុខនីន**	២២- ព្រិន្ទបាលទោ	**អ៊ឹង**	**ចន្ថា**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ចរសា. ១២០៣. ១៩៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១២

លេខៈ ... ច.ល

រាជធានីភ្នំពេញ ... ខែ ... ឆ្នាំ២០១២

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/១៩០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

តែងតាំង

ឯកឧត្តម ប្រាក់ ចំរើន

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៦៩.១២០៣-១៩៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១២

លេខ: ១៩៧ ប.ល

ដើម្បីចម្លងចេញ

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១២

[illegible]ទី១រាជរដ្ឋាភិបាល

[illegible] សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/១៩១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ត្រាស់បង្គាប់

បញ្ចប់មុខតំណែងឯកឧត្តម ស្វ ស៊ីឌីម មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយទទួលមរណភាព ។

សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ គង់ សំអុល ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ត្រូវអនុវត្តនូវព្រះរាជក្រឹត្យនេះ ។

៣១៣-១២០៣-១៩៦

បានប្រថាប់ព្រះរាជលញ្ឆករហើយ

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០១២

(ហត្ថលេខា)

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ ០០៤ ១៦២ ......រ.ចជ
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

(ត្រា និង ហត្ថលេខា)

p

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/ ១៩៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្រមខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានកែសម្រួលឋានន្តរស័ក្តិលោកជំទាវ **ចាន់ សំដារិន្ទ** ពីអនុមន្ត្រីថ្នាក់លេខ **១១** ទៅឧត្តមមន្ត្រីថ្នាក់លេខ **៦** នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល **ជាករណីពិសេស** នៅក្រសួងព្រះបរមរាជវាំង ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង ,ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១២

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៦.១២០៣.១៩៧

លេខ ១៩៣ ច.ល
ដើម្បីចម្លងចែក
ភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០១២
អគ្គលេខាធិការរងទី១ទីស្តីការគណៈរដ្ឋមន្ត្រី
ឈិយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/១៩៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានដាក់មន្ត្រីរាជការ**០៣ រូប** ឱ្យចូលនិវត្តន៍ ក្នុងក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងព្រះបរមរាជវាំង ដោយរក្សាមុខដំណែងជាអ្នកនយោបាយ មានដូចខាងក្រោម ៖

១-ឯកឧត្តម **អ៊ី ឯម** ចូលនិវត្តន៍ ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រីថ្នាក់លេខ ១ ចាប់ពីថ្ងៃទី**០១ ខែឧសភា ឆ្នាំ២០១២**
២-ឯកឧត្តម **អ៊ី វិជ្ជាវ៉ារុធ** ចូលនិវត្តន៍ ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រីថ្នាក់លេខ ៣ ចាប់ពីថ្ងៃទី**០១ ខែសីហា ឆ្នាំ២០១២**
៣-ឯកឧត្តម **មូល សារឿន** ចូលនិវត្តន៍ ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រីថ្នាក់លេខ ៥ ចាប់ពីថ្ងៃទី**០១ ខែមីនា ឆ្នាំ២០១២**

មាត្រា ២: បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៩. ១២០៣. ១៩៧

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១២

បានយកសេចក្តី...៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ... ឆ្នាំ២០១២
អគ្គលេខាធិការ... ទីស្តីការគណៈរដ្ឋមន្ត្រី
...សមមុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/ ១៩៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំនៃក្រសួងពាណិជ្ជកម្ម ចំនួន ១៦ រូប មានស្នាដៃល្អ
ក្នុងការបំពេញភារកិច្ចបម្រើជាតិ មាតុភូមិ
នូវ

ក-គ្រឿងឥស្សរិយយស ជាតូបការ

១- ឯកឧត្តម **គឹម ស៊ីថន**
២- ឯកឧត្តម **ទ៉ា ជាង**
៣- ឯកឧត្តម **កែវ សុខណៃ**

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

១- ឯកឧត្តម **ម៉ៅ ថូរ៉ា**
២- ឯកឧត្តម **ប៉ាន សូរស័ក្តិ**
៣- ឯកឧត្តម **ឱក ប៊ុង**
៤- ឯកឧត្តម **តាន់ ស៊ិនគូ**

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

១- ឯកឧត្តម **ច័ន្ទ នរ៉ា**
២- ឯកឧត្តម **ឈុន ជារ៉ា**
៣- ឯកឧត្តម **ម៉េង សុធី**
៤- លោកជំទាវ **តឹកហ៊ែត គំរ៉ង**
៥- ឯកឧត្តម **សុខ រុន**

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

១- ឯកឧត្តម **ហូ សារ៉ាន់**
២- ឯកឧត្តម **ឌិត ធីណា**
៣- ឯកឧត្តម **ភាន ច័ន្ទមេត្តា**

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

ឯកឧត្តម **ឯម សោភ័ណ្ឌ**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

១៧៨៥.១២០៣.១៩៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១២

បានឃើញ ច.ល
ដើម្បីជូនប្រកាស
រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មីនា ឆ្នាំ២០១២
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
[illegible] សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/១៩៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនត្តិយា មហារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្រមខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានប្តូរ និងតម្លើងប្រភេទក្របខ័ណ្ឌ លោកស្រី **ហែម ផល្លី** ពីមន្ត្រីក្នុងឋានន្តរស័ក្តិ ក្រមការដើមខ្សែថ្នាក់លេខ ៣ ទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល មន្ត្រីរាជការ ក្នុងឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ **១៤** **ជាករណីពិសេស** នៅក្រសួងសាធារណការ និងដឹកជញ្ជូន ។

មាត្រា ២ : ត្រូវបានប្តូរ និងតម្លើងប្រភេទក្របខ័ណ្ឌ លោកស្រី **ពិន ឧត្តរា** ពីមន្ត្រីបច្ចេកទេសបឋម ថ្នាក់លេខ **៧** ទៅក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ **១៤** នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ **ជាករណីពិសេស** នៅក្រសួងសាធារណការ និងដឹកជញ្ជូន ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣១៣.១២០៣.២០០

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១២

បានជូន ០ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១២
រដ្ឋមន្ត្រីប្រចាំការទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សាយ សុខា

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៩. អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល។

សម្រេច

មាត្រា១៖

ត្រូវបានកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព លើផ្ទៃដីសរុបចំនួន ១.៨៦៥ហិកតា (មួយពាន់ ប្រាំបីរយ ហុកសិបប្រាំហិកតា) ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ សម្រាប់ផ្តល់ជូនក្រុមហ៊ុន សុខ សំណាង ឌីវេឡុបមេន ធ្វើការវិនិយោគអភិវឌ្ឍន៍ឈើស៊ុយផ្ដំណាំកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូ រយៈពេល៧០ឆ្នាំ ដែលមានទីតាំង និងនិយាមកា ដូចមានក្នុងផែនទីភ្ជាប់នឹងលិខិតលេខ ២០៤ សជណ.កស ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០១២ ជាឧបសម្ព័ន្ធ។

p

មាត្រា២៖

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣៖

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មី/៣ ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី "ដើម្បីគោរពជូនជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤០ អនក្រ.បក

អនុក្រឹត្យ
ស្ដីពី
ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល។

សម្រេច

មាត្រា១៖

ត្រូវបានកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព លើផ្ទៃដីសរុបចំនួន ៩.១២៩(ប្រាំបួនពាន់ មួយរយ ម្ភៃប្រាំបួន)ហិកតា ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តព្រះវិហារ សម្រាប់ផ្ដល់ជូនក្រុមហ៊ុន **ខេមបូឌាន ប្លូ ហេវិន លីមីតធីត** (Cambodian Blue Haven Limited) ធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិកម្ម និងដំណាំកសិ-ឧស្សាហកម្ម រយៈពេល៧០ឆ្នាំ ដែលមានទីតាំង និងនិយាមកា ដូចមានក្នុងផែនទីភ្ជាប់នឹងលិខិតលេខ ១៨៥ សជណ.កស ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១២ ជាឧបសម្ព័ន្ធ។

p

មាត្រា២៖

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣៖

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិនា ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី "ដើម្បីគោរពជូនជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤១ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល។

សម្រេច

មាត្រា១៖

ត្រូវបានកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព លើផ្ទៃដីសរុបចំនួន ១.១៩៥ហិកតា (មួយពាន់ មួយរយ កៅសិបប្រាំហិកតា) ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ សម្រាប់ផ្តល់ជូនក្រុមហ៊ុន **ហួត ម៉េងរីតា ខូអិលធីឌី** ធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូ រយៈពេល៧០ឆ្នាំ ដែលមានទីតាំង និងនិយាមកា ដូចមានក្នុងផែនទីភ្ជាប់នឹងលិខិតលេខ ២០៤ សជណ.កស ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០១២ ជាឧបសម្ព័ន្ធ។

p

មាត្រា២៖

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣៖

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី "ដើម្បីគោរពជូនជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៧.អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៣២១ ហិកតា ក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង ស្ថិតនៅក្នុងភូមិសាស្ត្រ ខេត្តកោះកុង

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៨ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ២៧៨ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា១

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៣២១(បីរយម្ភៃមួយ) ហិកតាក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង ស្ថិតក្នុងភូមិសាស្ត្រខេត្តកោះកុង ក្រោមល័ក្ខខ័ណ្ឌសម្បទាន ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកាដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ១៩៩២ សជណ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា២:

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

មាត្រា៣:

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៤:

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តកោះកុង ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៨.៥៦៨ ហិកតា ក្នុងតំបន់ឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ "គិរីរម្យ" ស្ថិតនៅក្នុងភូមិសាស្រ្ត ខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ បង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែ ឧសភាឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងប្បញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១២ ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា១

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៨.៥៦៨ (ប្រាំបីពាន់ប្រាំរយហុកសិបប្រាំបី) ហិកតា ក្នុងតំបន់ឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ "គីរីរម្យ" ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ក្រោមល័ក្ខខ័ណ្ឌសម្បទាន ដើម្បីធ្វើអាជីវកម្មចៀរជ័រស្រល កាប់ឆ្ការ ផ្លាស់ប្តូរដាំដើមស្រល់បន្ថែម និងបង្កើនរោងចក្រកែច្នៃផលិតផលជ័រស្រល់ ដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ១៥៨១ សជណ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា២:

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

មាត្រា៣:

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៤:

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ [illegible] ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤

រាជកិច្ច

ឯកសារកាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៧៣.អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ ៥៧អនក្រ.បកចុះថ្ងៃទី០៧ ខែ មិថុនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦៣អនក្រ.បក ចុះថ្ងៃទី០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

សម្រេច

មាត្រា ១ : ប្រគល់ភារកិច្ចជូនមន្ត្រីរាជការនៃក្រសួងកិច្ចការនារីចំនួន ០៥ រូប ដែលមានសមាសភាពដូចខាងក្រោម ៖

១- លោកស្រី សៅ សុខា ឲ្យបំពេញមុខងារជាអគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ

p

២- លោក **ថេ ឈុនហាក់** ឲ្យបំពេញមុខងារជាអគ្គនាយករងនៃអគ្គនាយកដ្ឋានសមភាពយេនឌ័រ និងអភិវឌ្ឍន៍សេដ្ឋកិច្ច

៣- លោកស្រី **ឡុង សុផល្លី** ឲ្យបំពេញមុខងារជាប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

៤- លោកស្រី **តែ រួចលីម** ឲ្យបំពេញមុខងារជាប្រធាននាយកដ្ឋានផែនការស្ថិតិ

៥ លោកស្រី **ចាន់ សុធាវី** ឲ្យបំពេញមុខងារជាប្រធានផ្នែកនីតិកម្មនៃអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
អគ្គលេខាធិការរាជរដ្ឋាភិបាល
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
ដូចមាត្រា ២
រាជកិច្ច
ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ២៨៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញ អនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក **ហ៊ឹម ទិបុលផល** ជាប្រធាននាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជំនួសលោក **ផែក សារិន** ដែលត្រូវបានចូលនិវត្តន៍។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ មីនា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៧៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការតែងតាំង ប្រគល់ភារកិច្ច និងផ្ទេរភារកិច្ច ជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យ លេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

សម្រេច

មាត្រា ១: ត្រូវបានតែងតាំងលោក **យស មុនីរ៉ាត់** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានធនធានរ៉ែ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជំនួសលោក **អ៊ិច ម្ញូរ៉ា** ដែលត្រូវបានទទួលភារកិច្ចថ្មី ។

មាត្រា ២: ត្រូវបានប្រគល់ភារកិច្ច ជូនមន្ត្រីរាជការ ចំនួន ០៥ រូប នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល៖

១. លោក **ស៊ឹម ស៊ីសុខាលី** ឲ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានធនធានរ៉ែ ជំនួសលោក **ជួរ ជេតនីវណ្ណ** ដែលត្រូវបានទទួលភារកិច្ចថ្មី

២ លោកស្រី **ឡាយ ណាវីន** ឲ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានឧស្សាហកម្ម ជំនួសលោក **កែវ សុវត្ថិ** ដែលត្រូវបានដាក់ឲ្យចូលនិវត្តន៍

៣ លោក **ប្រ៉ា វិចិត្រ** ឲ្យបំពេញមុខងារជាប្រធាននាយកដ្ឋានធនធានរ៉ែ ជំនួសលោក **យស មុនីរ៉ាត់** ដែលត្រូវបានទទួលភារកិច្ចថ្មី

p

៤ លោក **នួន នរិន្ទ** ឲ្យបំពេញមុខងារជាប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានរ៉ែ ជំនួសលោក **ស៊ឹម ស៊ីសុខាលី** ដែលត្រូវបានទទួលភារកិច្ចថ្មី

៥ លោក **ស៊ុយ ឌីម៉េង** ឲ្យបំពេញមុខងារជាប្រធាននាយកដ្ឋានឧស្សាហកម្មតូច សិប្បកម្ម ជំនួសលោកស្រី **ឡាយ ណារីន** ដែលត្រូវបានទទួលភារកិច្ចថ្មី

មាត្រា ៣: ត្រូវបានផ្ទេរភារកិច្ចលោក **ជួរ ដេតឆិទន្ត** ពីអគ្គនាយករង នៃអគ្គនាយកដ្ឋានធនធានរ៉ែ ឲ្យទៅជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

មាត្រា ៤: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ មាត្រា ២ និងមាត្រា ៣ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ១៦ ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៤៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងផ្លាស់ប្តូរមុខងារ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១ : ត្រូវបានតែងតាំងផ្លាស់ប្តូរមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

១-ឧត្តមសេនីយ៍ឯក **ណោប សន** អត្តលេខ ០០០៨១៧ ជា នាយរងសេនាធិការចំរុះ និងជា នាយក ទីចាត់ការចលនូប្បត្តម្ភ អគ្គបញ្ជាការដ្ឋាន

២-ឧត្តមសេនីយ៍ឯក **អ៊ុង សារិទ្ធ** អត្តលេខ ០០១១០០ ជា នាយរងសេនាធិការចំរុះ និងជា មេបញ្ជាការរង និងជា នាយសេនាធិការ បញ្ជាការដ្ឋានអង្គរក្ស

៣-ឧត្តមសេនីយ៍ទោ **ឈន សារ៉ាណេ** អត្តលេខ ០០៤៥៥៤ ជា នាយរងសេនាធិការចំរុះ និងជា មេបញ្ជាការរង បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការដ្ឋាន

៤-ឧត្តមសេនីយ៍ទោ **ម៉ុល ស៊ីនួន** អត្តលេខ ០០៣៤១១ ជា នាយរងសេនាធិការចំរុះ អគ្គបញ្ជាការដ្ឋាន

p

៥-ឧត្តមសេនីយ៍ទោ **មាស វ៉ែន** អត្តលេខ ០០០២៧១ ជា នាយរងសេនាធិការចំរុះ អគ្គបញ្ជាការដ្ឋាន

៦-ឧត្តមសេនីយ៍ទោ **គីម សំអាន** អត្តលេខ ០០០៣១៦ ជា នាយរងសេនាធិការចំរុះ អគ្គបញ្ជាការដ្ឋាន

៧-ឧត្តមសេនីយ៍ទោ **គង់ វណ្ណា** អត្តលេខ ០០១៩៣៩ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

៨-ឧត្តមសេនីយ៍ទោ **ស៊ុន អ៊ុន** អត្តលេខ ០០០៥២៣ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

៩-ឧត្តមសេនីយ៍ត្រី **ជូ សុរិយ៉ារ៉ុង** អត្តលេខ ០០១៣៨៩ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

១០-ឧត្តមសេនីយ៍ត្រី **គីម ផាន** អត្តលេខ ០០០៦៣៥ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

១១-ឧត្តមសេនីយ៍ត្រី **ឈុច ឧត្តមរិទ្ធ** អត្តលេខ ០០០៨៥០ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

១២-ឧត្តមសេនីយ៍ត្រី **ជួប ពិសិដ្ឋ** អត្តលេខ ០០២៤៤០ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

១៣-ឧត្តមសេនីយ៍ត្រី **ឆន់ ម៉ុនតា** អត្តលេខ ០០០៨៤៩ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

១៤-ឧត្តមសេនីយ៍ត្រី **សៅ សុន្ធា** អត្តលេខ ០០២៤៤៣ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

១៥-ឧត្តមសេនីយ៍ត្រី **អ៊ុក ហាន** អត្តលេខ ០០២៤៧៨ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

១៦-ឧត្តមសេនីយ៍ត្រី **ឈួន ជឿន** អត្តលេខ ០០០៣២២ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

១៧-ឧត្តមសេនីយ៍ត្រី **ចាត់ សុខៃ** អត្តលេខ ០០០៧៥៨ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

១៨-ឧត្តមសេនីយ៍ត្រី **ឥន្ទ ជាតិខេម** អត្តលេខ ០០២៨៧៩ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

១៩-ឧត្តមសេនីយ៍ត្រី **ឡូន ទិចិត្រ** អត្តលេខ ០១០៤៨៥ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

២០-ឧត្តមសេនីយ៍ត្រី **រស់ សារិទ្ធ** អត្តលេខ ០០៩៤០០ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

២១-ឧត្តមសេនីយ៍ត្រី **ម៉ុក ធុល** អត្តលេខ ០០៩៤១៣ ជា ទីប្រឹក្សា អគ្គមេបញ្ជាការ

២២-ឧត្តមសេនីយ៍ត្រី **សេត ម៉ានី** អត្តលេខ ០០១៥៨៥ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

២៣-ឧត្តមសេនីយ៍ត្រី **ខៀវ វណ្ណារិទ្ធ** អត្តលេខ ០០២២៤៩ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និង បណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៨៦ អនក្រ.តត

អនុក្រឹត្យ

ស្ដីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាបស្ដីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងការប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនកងឯកភាព ចំនួន ១១៨ និងបុគ្គល ចំនួន ៩៩៩ រូប ចំណុះកងរាជអាវុធហត្ថ នៃកងយោធពលខេមរភូមិន្ទ ដែលមានស្នាដៃក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម ៖

ក.មេដាយមាសការងារ

.ចំពោះកងឯកភាព

១-ការិយាល័យភស្តុភារ ស្នងការដ្ឋានភស្តុភារ បច្ចេកទេស កងរាជអាវុធហត្ថលើផ្ទៃប្រទេស

២-ការិយាល័យវិស្វកម្ម ស្នងការដ្ឋានភស្តុភារ បច្ចេកទេស កងរាជអាវុធហត្ថលើផ្ទៃប្រទេស

